ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៩ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០

រៀបចំដោយៈ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយៈ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលាក្រុមប្រឹក្សាបច្ចេកទេសលើកទី៩សម្រាប់ឆ្នាំ២០២០ នៅបន្ទប់ប្រជុំខនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម យិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការមួយចំនួនដែលពាក់ព័ន្ធ។ ក្នុងនោះសមាជិកនៅតាមបណ្តាក្រសួង និងអង្គការពាក់ព័ន្ធនៅក្រុងភ្នំពេញត្រូវបានមកចូលរួមផ្ទាល់នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយឡែកសមាជិកនៅតាមខេត្តចូលរួមតាមរយៈ វីអូខនហ្វើរេន (Bluejeans)។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ជម្រាបជូនសមាជិក សមាជិកានៃអង្គសិក្ខាសាលាឱ្យបានយល់ដឹងពីស្ថានភាពប្រឈមនៃមេរោគអេដស៍ និងជំងឺអេដស៍នាពេលបច្ចុប្បន្នក្នុងចំណោមបុរសរួមភេទជាមួយបុរស និងក្រុមស្រីស្រស់។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឈឹម យិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកាក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ដែលបានអញ្ជើញចូលរួមផ្ទាល់ និងតាមរយៈវីដេអូខនហ្វើរេន។ នាឱកាសនោះ ឯកឧត្តមក៏បានជម្រាបជូនសមាជិកទាំងអស់ឱ្យបានយល់ថា ការតាមដាន ត្រួតពិនិត្យ និងការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ គឺជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាបច្ចេកទេស ដូច្នេះហើយទើបសិក្ខាសាលាក្រុមប្រឹក្សាបច្ចេកទេសត្រូវរៀបចំជាប្រចាំរៀងរាល់មួយខែម្តង ដើម្បីឱ្យការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ មានប្រសិទ្ធភាពក្នុងការលុបបំបាត់ការឆ្លងថ្មី គ្មានការស្លាប់ដោយសារជំងឺអេដស៍ និងគ្មានការរើសអើងដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ម្យ៉ាងវិញទៀតសិក្ខាសាលានេះបានចែករំលែកនូវការយល់ដឹង ក៏ដូចជាបទពិសោធន៍ពីគ្នាទៅវិញទៅមក ព្រមទាំងសំណូមពរនានា ឬក៏មានបញ្ហាទាក់ទងនឹងបញ្ហាអេដស៍លើកយកមកពិភាក្សាដើម្បីរកដំណោះស្រាយរួមគ្នា។

បន្ទាប់មកតំណាងអង្គការ FHI-360 បានធ្វើបទបង្ហាញអំពីស្ថានភាពទូទៅនៃក្រុមប្រឈមមុខខ្ពស់ទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស និងក្រុមស្រីស្រស់នៅប្រទេសកម្ពុជាតាមការប៉ាន់ប្រមាណអំពីលក្ខណៈប្រឈម និងចំនួនអត្រាផ្ទុកក្នុងចំណោមបុរសរួមភេទជាមួយបុរសដែលបានរកឃើញនៅឆ្នាំ២០១៩ បានឱ្យដឹងថាបុរសរួមភេទជាមួយបុរសមានចំនួន៨៧៨១៧នាក់ ក្នុងនោះមានអត្រាផ្ទុកមេរោគអេដស៍៤.០% និងអត្រាជំងឺកាមរោគមាន១៤.៥% រីឯក្រុមអ្នកបំប្លែងភេទមានចំនួន៦៣០០នាក់ ក្នុងនោះមានអត្រាផ្ទុកមេរោគអេដស៍៩.៦% និងអត្រាជំងឺកាមរោគមាន២៥.៥%។ ទន្ទឹមនឹងនោះបានរកឃើញថា មានកត្តាមួយចំនួនផ្សេងទៀតដែលជំរុញឱ្យក្រុមបុរសរួមភេទជាមួយបុរសមានការកើនឡើង

ពិសេសទៅលើយុវវ័យដែលកំពុងសិក្សានៅថ្នាក់មហាវិទ្យាល័យ ឬក៏ជាអ្នកធ្វើការងារនៅតាមហាងដូចជា សណ្ឋាគារ សម្អាងការ ហាងអ៊ុតសក់។ល។ ម្យ៉ាងទៀតទាក់ទងនឹងឥរិយាបទមួយចំនួនទៀតគឺ ពួកគាត់ដើរតួរជាស្ត្រី ហើយក្រុមនេះច្រើនធ្វើការទំនាក់ទំនងគ្នាតាមរយៈ Smart phone ដែលមាន App ដូចជា Face Book Twitter Instagram Snapchat ជាដើម ដោយមានការដោះដូរជាទឹកប្រាក់ ឬរបស់របរផ្សេងៗ ប៉ុន្តែការទិញលក់ផ្លូវភេទបុរសរួមភេទជាមួយបុរសមានប្រហែល១៤% រីឯក្រុមស្រីស្រស់មានរហូតដល់ ៤០% ។ ការសង្កេតរួមបង្ហាញថា ក្រុមបុរសរួមភេទជាមួយបុរសមានការលក់ ឬទិញផ្លូវភេទ និងការប្រើប្រាស់គ្រឿងញៀនច្រើនជាងក្រុមអ្នកបំប្លែងភេទ ប៉ុន្តែក្រុមអ្នកបំប្លែងភេទមានដៃគូច្រើនជាងក្រុមបុរសរួមភេទជាមួយបុរស។

តាមរបកគំហើញនៃការសិក្សាសាកល្បង HIV Self Testing ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញទៅលើក្រុមបុរសរួមភេទជាមួយបុរស ក្រុមអ្នកបំប្លែងភេទ និងស្ត្រីបំរើសេវាកម្សាន្តសប្បាយចំនួន១២០០នាក់ បានបញ្ជាក់ឱ្យដឹងថា ការប្រើប្រាស់ស្រោមអនាម័យទៀងទាត់ និងជាប់លាប់មានប្រហែលតែ៥០% ក្រុមអ្នកលាក់មុខប្រហែល៧០%មិនធ្លាប់ធ្វើតេស្តពីមុន ហើយក្នុង៧០%នេះជារួមអត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ក្នុងក្រុមបុរសរួមភេទបុរសមាន៧.៩% ក្រុមអ្នកបំប្លែងភេទមាន១០.៩% និងស្ត្រីបំរើសេវាកម្សាន្តសប្បាយមាន២.៥% និងមានការយល់ឃើញថា ការរួមភេទជាមួយភេទដូចគ្នាអត្រានៃការឆ្លងតិចតួច ឬមិនមានការឆ្លងតែម្តង។ ដូច្នេះតាមរយៈការសិក្សាខាងលើ ក្រសួងសុខាភិបាលបានដាក់ចេញនូវនិយាមប្រតិបត្តិសម្រាប់អនុវត្តក្នុងបទអន្តរាគមន៍បង្ការទៅលើក្រុមប្រឈមមុខ ដោយដាក់ឱ្យប្រើប្រាស់ការធ្វើតេស្តដោយខ្លួនឯង។

**បញ្ហាប្រឈម និងមេរៀនបទពិសោធន៍**

- ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមអ្នកបំប្លែងភេទ បានរកឃើញមានផ្ទុកមេរោគអេដស៍ប្រមាណ៣៨% មានវ័យក្មេងអាយុ ១៥-២៥ឆ្នាំ និងពាក់ព័ន្ធនឹងការលក់ភេទ។
- ចំនួនករណីរកឃើញមានផ្ទុកមេរោគអេដស៍ និងជំងឺស្វាយជាមធ្យមប្រហែល០២នាក់/ថ្ងៃ ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមអ្នកបំប្លែងភេទ (ទិន្នន័យកម្មវិធីឆ្នាំ២០១៩-២០២០) និងភាគច្រើននៃករណីរកឃើញមានផ្ទុកមេរោគអេដស៍ ដូចជានៅរាជធានីភ្នំពេញ (៥១%) ដែលពួកគេជានិស្សិត ជាបុគ្គលិកក្រុមហ៊ុន និងជាអ្នកសម្អាងការ។
- ឥរិយាបថរបស់ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមអ្នកបំប្លែងភេទ ជាអ្នកចូលចិត្តមានដៃគូច្រើន និងផ្លាស់ប្តូរជាប្រចាំ និងរួមភេទជាក្រុម ហើយប្រើប្រាស់ថ្នាំញៀន ថ្នាំសម្រើប ក្នុងពេលរួមភេទ និងមិនប្រើស្រោមអនាម័យ។

- ភាគច្រើននៃពួកគេមានផ្ទុកជំងឺកាមរោគ ក្នុងនោះបុរសរួមភេទជាមួយបុរសមាន ១៤.៥% និងក្រុមអ្នកបំប្លែងភេទមាន២.៥%។
- ការគិតរបស់ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមអ្នកបំប្លែងភេទគឺថា ការរួមភេទជាមួយភេទដូចគ្នាមិនមានការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ។
- បុរសរួមភេទជាមួយបុរស និងអ្នកបំប្លែងភេទចូលចិត្តប្រើគ្រឿងញៀន/ថ្នាំបង្កើនអារម្មណ៍ផ្លូវភេទ។
- ភាគច្រើនអ្នកដែលបានជួបជាមួយក្រុមការងារ គឺសុទ្ធតែមិនធ្លាប់បានជួបពីមុនមក និងក៏ជាអ្នកដែលមិនបានដឹងព័ត៌មានអំពីសេវា ហើយលាក់អត្តសញ្ញាណ។

**អ្វីដែលត្រូវធ្វើជាបន្ត និងចាំបាច់**

- បង្កើន និងពង្រឹងការផ្សព្វផ្សាយឱ្យក្រុមគោលដៅទទួលបានសេវា ជាពិសេស ទទួលបានការព្យាបាលដោយឱសថបង្ការការឆ្លងមេរោគអេដស៍ (PrEP) នៅមុនឥរិយាបថប្រឈម និងពង្រីកការផ្តល់មធ្យោបាយធ្វើតេស្តដោយខ្លួនឯង (Self-Testing)។
- ប្រើប្រាស់មធ្យោបាយដែលមានប្រសិទ្ធភាពក្នុងការទំនាក់ទំនងជាមួយក្រុមគោលដៅ។
- ពង្រឹងអន្តរាគមន៍បង្ការទៅតាមប្រភេទនៃក្រុមគោលដៅ ដោយប្រើប្រាស់សារអប់រំជាក់លាក់សម្រាប់ក្រុមគោលដៅនីមួយៗ។
- ពង្រឹងគុណភាពការផ្តល់ប្រឹក្សានៅមុន និងនៅក្រោយការទទួលបានសេវា។
- បន្តពង្រីកការផ្តល់សេវាអប់រំតេស្តឈាមនៅតាមសហគមន៍។
- ពង្រីកការផ្សព្វផ្សាយ និងផ្តល់ព័ត៌មានជាក់លាក់អំពីស្ថានភាពនៃការឆ្លង និងការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ហើយជួយបង្ហាញអំពីទីតាំង មធ្យោបាយ និងសេវាអប់រំការធ្វើតេស្ត មធ្យោបាយបង្ការ និងការព្យាបាលដែលនៅជិតពួកគេ។
- បញ្ឈប់ការយកស្រោមអនាម័យជាភស្តុតាង ក្នុងការដាក់បន្ទុកលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសក្រុមអ្នកបំប្លែងភេទជាស្ត្រី។
- បញ្ឈប់ការរើសអើង និងម៉ាក់ងាយក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសក្រុមអ្នកបំប្លែងភេទ ជាស្ត្រី ទាំងនៅទីសាធារណៈ នៅក្នុងសហគមន៍ នៅកន្លែងការងារ និងក្នុងគ្រួសារ។
- រៀបចំឱ្យមានសប្តាហ៍ធ្វើតេស្តឈាមដើម្បីសុខភាព និងសុវត្ថិភាពនៅទូទាំងប្រទេសក្នុងពេលតែមួយ ដោយភ្ជាប់ជាមួយការផ្តល់មធ្យោបាយបង្ការ ដូចជាស្រោមអនាម័យ ទឹករំអិល និងការពិនិត្យព្យាបាលជំងឺកាមរោគ។

- បញ្ចូល និងបង្កើនការផ្សព្វផ្សាយអំពីការយល់ដឹងទាក់ទងនឹងទំនោរផ្លូវភេទ និងអត្តសញ្ញាណភេទ នៅក្នុងសាលារៀន និងបញ្ឈប់ហិង្សាផ្លូវភេទ ការមើលងាយ ការគំរាមសម្លុត និងការធ្វើបាប។
- បញ្ចូលក្រុមអ្នកស្រឡាញ់ភេទដូចគ្នារាប់ទាំងក្រុមអ្នកបំប្លែងភេទជាស្ត្រី និងអង្គការសង្គមស៊ីវិល ជាអ្នករួមចំណែកក្នុងការផ្តល់ការអប់រំ និងការផ្សព្វផ្សាយអំពីមេរោគអេដស៍នៅក្នុងគណៈកម្មការឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/រាជធានីប្រយុទ្ធនឹងជំងឺអេដស៍។
- លើកទឹកចិត្ត និងគាំទ្រដោយការផ្តល់ការសហការដល់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសក្រុមអ្នកបំប្លែងភេទជាស្ត្រីក្នុងការស្វែងរកដៃគូ ឬអ្នកដែលគេមានទំនាក់ទំនងផ្លូវភេទជាមួយ ដើម្បីធ្វើតេស្តឈាម និងទទួលបានការព្យាបាល។

**មតិយោបល់៖**

- ខេត្តបាត់ដំបង ចំពោះ OW តើពួកគាត់មានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាកំរិតណា?
- តំណាងអង្គការ RHAC បានបញ្ជាក់ថា ពួកគាត់មានសមត្ថភាពក្នុការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដូចជា Facebook App.. និងអាចមើលទីតាំងដែលក្រុមប្រឈមរស់នៅតាមរយៈ Smart phone តាមរយៈជួបផ្ទាល់ ឬតាមរយៈ Online ដែលបានទទួលការបណ្តុះបណ្តាលពីអង្គការ RHAC។
- តំណាង UNAIDS៖ សំណូមពរ សូមពង្រឹងការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ទៅលើក្រុមប្រឈម ដោយសារមានករណីឆ្លងថ្មីច្រើន ជាពិសេសក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទដែលមានអាយុចាប់ពី១៨ទៅ១៩ឆ្នាំ។ ម្យ៉ាងទៀត បញ្ហាធ្វើតេស្តឈាមដោយខ្លួនឯងទៅលើពួកគាត់ ត្រូវធ្វើឱ្យបានទៀងទាត់ ពិសេសនៅទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តដែលប្រឈម។
- តំណាងអង្គការ KHANA សំណូមពរ ៖
  - ✓ ពង្រឹងកិច្ចសហការឱ្យបានទូលំទូលាយរវាងក្រសួង ខេត្ត អង្គការពាក់ព័ន្ធ ព្រោះប្រជាជនយើងមួយចំនួនគាត់នៅតែយល់ឃើញថាសព្វថ្ងៃប្រទេសកម្ពុជាយើងមិនមានបញ្ហាអេដស៍ទៀតទេ ។
  - ✓ សូមផ្តល់សៀវភៅច្បាប់អេដស៍ឱ្យបានដល់គ្រប់ទីកន្លែង។
  - ✓ សូមក្រសួងមហាផ្ទៃធ្វើយ៉ាងណាកុំឱ្យមានការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យា ដូចជាការផ្សព្វផ្សាយអំពីថ្នាំប៉ូវកំលាំងទាក់ទងនឹងផ្លូវភេទ ដែលជាហេតុបង្កដល់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ផងដែរ។
  - ✓ សូមចូលរួមផ្សព្វផ្សាយច្បាប់អេដស៍តាមប្រព័ន្ធ Facebook។

**ឯកឧត្តម** អគ្គលេខាធិការប្រធានអង្គប្រជុំក៏បានទទួលយកនូវសំណូមពរ និងការលើកឡើងរបស់សមាជិក នៃអង្គប្រជុំផងដែរ។ **ឯកឧត្តម** បានបន្តថា ទោះជាបច្ចុប្បន្នស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍បានថយចុះក៏ពិតមែន ប៉ុន្តែបញ្ហាអេដស៍នៅតែជាការប្រឈមមុខខ្ពស់ដដែល ចំពោះក្រុមប្រជាជនគន្លឹះពិសេសក្រុមបុរសរួមភេទជាមួយបុរស និងស្រីស្រស់ មានអត្រាឆ្លងមេរោគអេដស៍កើនឡើងខ្ពស់គួរឱ្យព្រួយបារម្ភ ម្យ៉ាងទៀតចំពោះក្រុមការងារបង្ការ មិនអាចបន្ធូរដៃបានទេ បើសិនជាយើងមិនយកចិត្តទុកដាក់បន្ថែម វានឹងផ្ទុះឡើងវិញ ព្រោះមេរោគអេដស៍មិនទាន់បានរកឃើញឱសថព្យាបាលទេ។

ចុងបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានថ្លែងអំណរគុណ ចំពោះលោក អ៊ឹម ចាន់រីដែលបានធ្វើបទបង្ហាញ និងសមាជិក សមាជិកាទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំ។

ឯកឧត្តម ក៏បានកំណត់យកការប្រជុំលើកក្រោយគឺ ថ្ងៃពុធ១២កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយបញ្ជាក់ថា នឹងរៀបចំកិច្ចប្រជុំទល់មុខគ្នានៅ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំពោះសមាជិកក្រុមប្រឹក្សាបច្ចេកទេសតាមក្រសួង និងតាមវីដេអូ-ខនហ្វើរេន(Bluejeans) ចំពោះសមាជិកនៅតាមខេត្ត។

ថ្ងៃពុធ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០
**អ្នកធ្វើរបាយការណ៍**

**ស៊ុំ ផល្លា**

បានពិនិត្យត្រឹមត្រូវ
**ប្រធាននាយកដ្ឋាន**
**ទាក់ទង និងចលនាប្រភពធនធាន**

**ហួត សេរីវឌ្ឍ**

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់
**អគ្គលេខាធិការ**

ឃើញ
12-11-20